# បុណ្យខួបឆ្នាំទី៤ នៃសន្និសីទប្រជារាស្ត្រឥណ្ឌូចិន

តាមពត៌មានពីទីក្រុងមូស្គូមកថា កាលពីថ្ងៃទី ២៨ កុម្ភៈ ១៩៦៩ វេលាម៉ោង ១៦ និង ៣០ នាទី នៅមុនពិធីបុណ្យខួបឆ្នាំទី ៤ រំលឹកដល់សន្និសីទនៃប្រជារាស្ត្រឥណ្ឌូចិននោះ ឯ. ឧ. ង្វៀន ថូ ចាន់ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ប្រចាំសហភាពសូវៀត និងលោក ត្រាំង យ៉ុង អាន អ្នកតំណាងស្តីទីនៃក្រុមរណសិរ្សសេរីការជាតិនៅមូស្គូ បានអញ្ជើញមកសំដែងការគួរសមចំពោះ សហ. ម៉ែន ស៊ុំ ផាវ ការធារីស្តីទីនៃស្ថានទូតយើង ។

នៅក្នុងឱកាសនោះអ្នកតំណាងប្រទេសវៀតណាម ទាំងពីរនាក់ បានសំដែងនូវមនោសញ្ចេតនាដ៏កក់ក្តៅ នៃប្រជារាស្ត្រវៀតណាម ថ្វាយចំពោះសម្តេចសហជីវិន ដែលព្រះអង្គទ្រង់ជាអ្នកផ្តើមនិងជាអ្នករៀបចំបាត់ចែងធ្វើសន្និសីទនេះ ហើយអ្នកតំណាងវៀតណាមបានស្នើសុំឲ្យ សហ. ម៉ែន ស៊ុំ ផាវ នាំនូវអំណរគុណដ៏ស្មោះ នៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងអាជ្ញាធរនៃរណសិរ្សសេរីការជាតិ ព្រមទាំងប្រជាពលរដ្ឋរបស់ខ្លួនទាំងអស់ មកថ្វាយសម្តេចព្រះប្រមុខរដ្ឋ និងជូនរាជរដ្ឋាភិបាល ។ អ្នកតំណាងវៀតណាមទាំងពីររូបនេះបានបន្ថែមទៀតថា ព្រះបញ្ញាញាណដ៏ឈ្លាសវៃនៃសម្តេចជាអម្ចាស់នេះ គឺជាវិភាគទានដ៏សក្តិសិទ្ធិមួយក្នុងការប្រយុទ្ធតស៊ូនៃប្រជារាស្ត្រវៀតណាម ប្រឆាំងនឹងអំពើឈ្លានពានរបស់ចក្រពត្តិនិយមនៅក្នុងប្រទេសខ្លួន ។

ម្យ៉ាងទៀត អ្នកតំណាងវៀតណាមទាំង ២ រូប បានរំលឹកឡើងវិញ នូវកតវេទិតាធម៌នៃប្រជារាស្ត្រវៀតណាម ចំពោះការគាំទ្រដ៏មុឺងម៉ាត់

និងប្រកបដោយមេត្រីភាព ដែលប្រទេសកម្ពុជាបានផ្តល់ជានិច្ចដល់ប្រទេសវៀតណាមកំពុងប្រយុទ្ធ ហើយនិងការគាំទ្រដល់សន្និសីទនៅប៉ារីសពីរឿងវៀតណាមនៅពេលថ្មីៗនេះទៀត ។

ចំណែកឯសហជីវិន ម៉ែន ស៊ុំអាន វិញ ក៏បានថ្លែងអំណរគុណដល់អ្នកការទូតវៀតណាមទាំងពីរនាក់ចំពោះការមកលេងនេះ និងចំពោះមនោសញ្ចេតនាប្រកបដោយមេត្រីភាពរបស់លោកចំពោះសម្តេចសហជីវិន និងចំពោះប្រទេសកម្ពុជា ដោយបានបញ្ជាក់ប្រាប់លោកទាំងពីរវិញថា រាជរដ្ឋាភិបាលនឹងទទួលដំណឹងនេះក្នុងពេលដ៏សមគួរ ។

តាមពត៌មានដែលនោះថា នៅឆ្នាំនេះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងអាជ្ញាធរនៃរណសិរ្សសេរីការជាតិវៀតណាម បានបញ្ចេញនូវសព្ទសញ្ញារំលឹកឡើងវិញអំពីអនុស្សាវរីយ៍នៃសន្និសីទប្រជារាស្ត្រឥណ្ឌូចិន ។ ហេតុដូច្នេះហើយបានជាអ្នកដំណាងប្រទេសវៀតណាមខាងជើង និង អ្នកដំណាងរណសិរ្សសេរីការជាតិបានបំពេញបេសកកម្មនេះនៅគ្រប់ស្ថានទូតខ្មែរយើងទាំងអស់ មិនមែននៅតែក្នុងក្រុងមូស្គូនេះមួយទេ ។

សន្និសីទនៃប្រជារាស្ត្រឥណ្ឌូចិននេះ បានតាក់តែងឡើងដោយពិតតាមព្រះបញ្ញាញាណដ៏សប្បុរស មិនអាចប្រកែកបាននៃសម្តេចសហជីវិននិងសង្គមរាស្ត្រនិយមដល់ប្រទេសវៀតណាម ។ ប៉ុន្តែដូចយើងបានកត់សំគាល់ឃើញថាជាការគួរឲ្យឆ្ងល់ដែរ ដែលមិត្តវៀតណាមហាក់ដូចជាប្រទះតែនឹងសតិវិបល្លាសជានិច្ច ចំពោះរឿងហេតុផ្សេងៗនៅក្នុងសមាជ, ការប្រជុំនានា ឬ ការប្រមូលជាអន្តរជាតិ ឬ អន្តរជាតិនិយម ក្នុងការគាំទ្រមូលហេតុរបស់ខ្លួន ។